**ទុត្ថា**

**"នេះគឺជារឿងរ៉ាវរបស់ក្មេងស្រីម្នាក់ដែលគាត់ចង់និយាយពាក្យសុំទោសតែមិនអាចនៅរួច "**

អ្នកស្រីសោភ័ណ្ឌអញ្ជើញមកដល់ហើយ ។
គាត់មានអាយុ ៣៨ ឆ្នាំ។
អ្នកស្រីសោភ័ណ្ឌ...តើអ្នកនឹងប្រាប់ពួកយើងអំពីរឿងរ៉ាវដែលកើតមានកាលពីពេលនោះដែររឺទេ?

**សុខលី**

នេះគឺជាឆ្នាំ ១៩៧៦។ ខ្ញុំអាយុ ៧ឆ្នាំ។
យើងរស់នៅក្នុងខ្ទមតូចមួយ មានម៉ែ បងប្រុសខ្ញុំពីរនាក់ ប្អូនស្រីតូចរបស់ខ្ញុំ និងខ្ញុំ។
យប់មួយនោះ ខ្ញុំភ្ញាក់ដឹងខ្លួនឡើង។
ខ្ញុំឃ្លានខ្លាំងណាស់។
កាលណោះ ខ្ញុំឃើញជន្លេនធាត់មួយ។ ខ្ញុំចង់ហូបវាណាស់ ប៉ុន្តែនៅពេលដែលវា វាក្នុងមាត់ខ្ញុំ ខ្ញុំក៏ខ្ជាក់វាចេញ ហើយក្អួត។
ឥឡូវនេះខ្ញុំក្ងួរពោះខ្លាំងណាស់។
ខ្ញុំក៏នឹកឃើញដល់ពាងអង្ករដែលពុកបានលាក់អង្ករដែលនៅសេសសល់បន្តិចបន្តួច។ ពុកថាអង្ករនេះគឺសំរាប់ហូបនៅពេលដែលចាំបាច់បំផុត គាត់លាក់អង្ករនោះទុកតាំងពីមុនពេលគេយកគាត់ទៅរៀនសូត្រម្ល៉េះ
ខ្ញុំនឹកឃើញដល់ពាងអង្ករ......ខ្ញុំស្រម៉ៃដល់រសជាតិដ៏

| | |
|---|---|
| ឆ្ងាញ់របស់អង្ករ។<br>ហាក់ដូចជាមានអ្វីធ្វើអោយខ្ញុំដើរទៅកាន់ពាងអង្ករ...<br>គ្មានអ្វីអាចបញ្ឈប់ខ្ញុំបានទេ។ ខ្ញុំក៏ភ្ញាក់ឡើង ហើយដើរលបៗកាត់អ្នកដ៏ទៃទៀតដែលកំពុងដេកលក់។<br>ដើរលបៗ....លបៗ....ពោះខ្ញុំកូលីខ្លាំងណាស់។<br>ខ្ញុំក៏ឈប់។ តើគេមានលឺពោះខ្ញុំកូអត់ហ្ន៎?<br>គ្មានអ្នកណាលឺទេ។ គេដេកលក់អស់ហើយ។ ដៃម៉ែខ្ញុំឱបប្អូនស្រីតូចខ្ញុំជាប់។ មុខប្អូនស្រីខ្ញុំហើមដោយសារតែខ្វះអាហារហូបចុក។<br>ដើរលបៗ........លបៗ............<br>ខ្ញុំមានអារម្មណ៍ថាម្រាមដៃខ្ញុំប៉ះពាងអង្ករហើយ។<br>ខ្ញុំខំអត់ដង្ហើម ខ្ញុំបើកគំរបពាងអង្ករយឺតៗ។ ដៃខ្ញុំលូកចូលទៅក្នុងពាង ច្បាមយកអង្ករមួយក្តាប់ហើយក៏ប្រញាប់ដាក់ចូលទៅក្នុងមាត់ដែលកំពុងឃ្លាន។<br>ខ្ញុំបៀមអង្ករក្នុងមាត់។នៅពេលដែលអង្ករទន់ល្មមហើយ ទើបខ្ញុំទំពារ។ អង្ករមានរសជាតិផ្អែមឆ្ងាញ់ណាស់ ហើយស្រួលលេបទៀត។<br>ខ្ញុំចង់ហូបហើយហូបទៀត។<br>ព្រឹកឡើងប្អូនស្រីរបស់ខ្ញុំស្រែកឡើងថា......<br><br>**ធារី**<br>**" ម៉ែ មើលន៎ យប់មិញមានអ្នកណាបើកពាងអង្ករ "** | **សំលេងភ្លេង** |

**សុខលី**

ខ្ញុំក្រឡេកមើលទៅពាងអង្ករ ហើយឃើញគំរបពាងហើបឡើង។ ខ្ញុំមិនបានបិទវាអោយបានស្រួលបួល។ ម៉ែនិយាយថា.....

**សុវណ្ណា**

**"ប្រហែលជាកណ្តុលចូលស៊ីហើយ។ ចាំយប់នេះម៉ែនឹងបិទអោយជិត។ ព្រោះអង្ករនេះជារបស់យើងទាំងអស់គ្នា"**

**សុខលី**

ខ្ញុំចង់តែស្រែកថា : **"ម៉ែ ! គឺខ្ញុំ...ខ្ញុំគឺជាអ្នកលួចអង្ករពីគ្រួសារ....ម៉ែអត់ទោសអោយខ្ញុំផង.."**

ប៉ុន្តែខ្ញុំគ្មាននិយាយអ្វីទាំងអស់។

ខ្ញុំជាមនុស្សមិនល្អ ហើយខ្ញុំក៏ដឹងថា ម៉ែដឹងថាខ្ញុំជាអ្នកលួចដែរ។ មានម្តងនោះម៉ែធ្លាប់ប្រាប់កូនៗថា ត្រូវធ្វើជាមនុស្សល្អ។ អំពើអាក្រក់ដែលយើងបានប្រព្រឹត្តនោះវានឹងតបស្នងមកវិញនូវបាបកម្ម ហើយជាតិក្រោយយើងនឹងកើតជា ពស់ ខ្យងឬជង្កូវ។ ប៉ុន្តែបាបកម្មនឹងសាបសូន្យទៅវិញ នៅពេលដែលយើងសារភាពនូវកំហុក ហើយសូមទោស ។

ខ្ញុំចង់សារភាពណាស់។ ខ្ញុំចង់សុំទោសណាស់។

ប៉ុន្តែខ្ញុំគ្មាននិយាយអ្វីទាំងអស់ ហើយខ្ញុំនៅស្ងៀម។

ខ្ញុំចង់សារភាព។ ខ្ញុំចង់ទទួលទោស។
ខ្ញុំមិនបាននិយាយអ្វីសោះ។
ខ្ញុំស្អប់ម៉ែណាស់ ដែលម៉ែមិនដាក់ទោសខ្ញុំ ហើយខ្ញុំក៏ស្អប់ខ្លួនឯងដែរ ដែលខ្ញុំស្អប់ម៉ែ។

**សុខលី**

ឥឡូវនេះខ្ញុំអាយុ៣៩ឆ្នាំហើយ។
ប្អូនតូចខ្ញុំស្លាប់ដោយសារគ្មានអីហូបនៅឆ្នាំ ១៩៧៧ ហើយបន្តិចក្រោយមកម៉ែក៏ស្លាប់ដែរ។គេស្នើបងប្រុសខ្ញុំអោយចូលក្នុងកងយុវជន។ ខ្ញុំមិនដែលទទួលដំណឹងពីគាត់សោះ។
ខ្ញុំនៅមានជីវិត។
ជីវិតរបស់ខ្ញុំល្អគ្រាន់បើដែរ...ខ្ញុំបានរៀនសូត្រ ហើយបានក្លាយទៅជាវេជ្ជបណ្ឌិត។ រាល់ពេលយប់ត្រជាក់ ខ្ញុំតែងតែនឹកឃើញកំហុសរបស់ខ្លួនឯង។ ខ្ញុំដឹងថា

**បទបំពេរ**

**" ទឹកចិត្តម្តាយ "**

**(និពន្ធ និងច្រៀងដោយ កញ្ញា សុខលី ~ មានជាស៊ីឌី)**

**នេះហើយចិត្តម្តាយ ទោះជិតឬឆ្ងាយ**
**គិតមិនសោះសូន្យ អាក្រក់ឬល្អ**
**ក៏នៅតែកូន នេះហើយជាក្បួន**
**ចងកូននិងម្តាយ ។**

| | |
|---|---|
| កាលណោះខ្ញុំគ្រាន់តែជាក្មេងស្រីតូចម្នាក់ប៉ុណ្ណោះ។ ខ្ញុំដឹងថាកាលណោះភាពស្រេកឃ្លានអាចផ្លាស់ប្ដូមនុស្សអោយទៅជាសត្វដែលហ៊ានធ្វើអ្វីៗទាំងអស់អោយតែបានហូប។<br>ប៉ុន្តែកំហុសដែលខ្ញុំបានធ្វើនៅជាប់ជាមួយខ្ញុំជានិច្ច។ បើមាននរណាម្នាក់មកជួយខ្ញុំ មិនដឹងជាល្អយ៉ាងណាទេ។ បើម៉ែរស់ឡើងវិញ មិនដឹងជាល្អ យ៉ាងណាទេ... ដើម្បីអោយខ្ញុំបានសារភាពចំពោះមុខគាត់នូវបាបកម្មដែលខ្ញុំបានសាង ដែលខ្ញុំមិនហ៊ានសារភាពកាលពីខ្ញុំអាយុ៧ឆ្នាំ។ | **ចំរៀង ថតទុក សច្ចាប្រណិធាន**<br>**ខ្មែររស់អបយស ពូជពង្សធ្លាប់ខ្ពស់**<br>**ផត់ពីញីញាំ ឥឡូវបាត់អស់**<br>**បាត់ភាពរឹងមាំ រស់នៅអត់ទ្រាំ**<br>**ទម្រាំមរណា។**<br>**រីក៏**<br>- **សូមអោយដើមឈើរមានសេរីភាពក្នុងរីកលូតលាស់។**<br>- **សូមអោយស្ករត្នោតជៀសផុតពីការស្ដីបន្ទោស។**<br>- **សូមអោយព្រលឹងខ្មោចបិសាចចេញចាកឆ្ងាយពីប្រទេសកម្ពុជា។**<br>- **សូមអោយសេចក្ដីសុខសន្តិភាពកើតមានឡើងសារជាថ្មីម្ដងទៀតដល់ជនគ្រប់រូបដែលរស់រានមានជីវិតនៅលើទឹកដីនេះ។** |